**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

ភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

# មតិស្វាគមន៍

តាងនាមឱ្យបុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ ខ្ញុំមានកិត្តិយសសូមបង្ហាញជូនលោកអ្នកនូវទំព័រដ្ឋានអប់រំកម្ពុជានៅលើទំព័រអាំងទែណែត ។ ទំព័រដ្ឋាននេះត្រូវបានរៀបចំឡើងដោយបុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ ឧបត្ថម្ភដោយអង្គការ Aide et Action និងកិច្ចសហប្រតិបត្តិការបារាំង។

ទំព័រដ្ឋាននេះធ្វើឡើងសម្រាប់លោកអ្នកដែលកំពុងបម្រើការងារក្នុងវិស័យអប់រំនៅ បឋមសិក្សា និងនៅមធ្យមសិក្សា មានជាអាទិ៍ សិស្ស គរុសិស្ស គរុនិស្សិត គ្រូបង្រៀនកម្រិតមូលដ្ឋាន សាស្ត្រាចារ្យ គ្រូឧទ្ទេស នាយកសាលា អធិការអប់រំ ប្រធានការិយាល័យអប់រំស្រុក-ខណ្ឌ និងប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុងនានា ។

អាំងទែណែតជាបណ្ណាល័យទំនើបស្របតាមយុគសម័យដែលគេហៅថា « *សង្គមព័ត៌មាន* »។ តាមរយៈការអានលើកញ្ចក់កុំព្យូទ័រនេះ លោកអ្នកនឹងទទួលបានចំណេះដឹងដែលមានសារៈសំខាន់ ទាក់ទងនឹងឯកសារបណ្តុះបណ្តាលជាភាសាខ្មែរ និងជាភាសាបារាំង ព្រមទាំងឯកសារណែនាំជាផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់បង្រៀន និងរៀន ។ ម៉្យាងវិញទៀត រូបភាពដ៏សម្បូរបែបអាចជួយសម្រួលឱ្យលោកអ្នកនិងប្អូនៗទាំងអស់ងាយយល់ព្រមទាំងចងចាំបានយូរនិងផ្តល់នូវទិន្នន័យសម្រាប់រិះគិតកម្រិតខ្ពស់ទៀតផង ព្រោះយើងទាំងអស់គ្នាមានគោលដៅធ្វើ ***កំណែទម្រង់ ពីការអប់រំដើម្បីចងចាំមកការអប់រំមួយដែលបណ្តុះការគិតកម្រិតខ្ពស់ក្នុងការដោះស្រាយបញ្ហាជាក់ស្តែងនិងការបង្កើតថ្មី*** ដែលសង្គមជាតិយើងកំពុងត្រូវការ។

ទំព័រដ្ឋាននេះក៏ជារបស់លោកអ្នកដែរ ។ ខ្ញុំសូមស្វាគមន៍ជានិច្ចនូវរាល់គំនិតឬសំណូមពរផ្សេងៗដែលជាការចូលរួមរបស់លោកអ្នក។

សូមលោកអ្នកទាក់ទងជាមួយក្រុមអ្នកនិពន្ធរបស់វិទ្យាស្ថានជាតិអប់រំ។

សូមអរគុណ និងសូមរីករាយក្នុងការប្រើប្រាស់ទំព័រដ្ឋាននេះ។

**នាយកវិទ្យាស្ថានជាតិអប់រំ**